អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# គម្រោងថវិកាកែសម្រួលរបស់ អ.វ.ត.ក សម្រាប់ឆ្នាំ ២០១៦-២០១៧

គម្រោងថវិកាកែសម្រួលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ឆ្នាំ ២០១៦-២០១៧ ត្រូវបានអនុម័តដោយក្រុមប្រទេសដែលមានចំណាប់អារម្មណ៍លើការងាររបស់ អ.វ.ត.ក នៅបុរីញ៉ូយក សហរដ្ឋអាមេរិក និងត្រូវបានផ្សព្វផ្សាយលើគេហទំព័រ អ.វ.ត.ក ហើយនាពេលនេះ។

គម្រោងថវិកាកែសម្រួលសម្រាប់ឆ្នាំ ២០១៧ នេះ មានទឹកប្រាក់សរុបចំនួន ៣០,១៣ លានដុល្លារអាមេរិក ដែលក្នុងនោះភាគីអន្តរជាតិ គ្រោងចំណាយចំនួន ២៣,៧៦ លានដុល្លារអាមេរិក និង ភាគីជាតិ គ្រោងចំណាយចំនួន ៦,៣៧ លានដុល្លារអាមេរិក។ គម្រោងថវិកាសម្រាប់ឆ្នាំ ២០១៦ ត្រូវបានកែសម្រួលដោយឈរមូលដ្ឋាននៃការចំណាយសរុបចំនួន ៣០,៦១ លានដុល្លារ ដែលក្នុងនោះភាគីអន្តរជាតិចំណាយថវិកាអស់ចំនួន ២៤,០៦ លានដុល្លារអាមេរិក និងភាគីជាតិចំណាយថវិកា ៦,៦៤ លានដុល្លារអាមេរិក។

គម្រោងថវិកាកែសម្រួលសម្រាប់ឆ្នាំ ២០១៦ និង២០១៧ បានកើនឡើងចំនួន ១,៩៤ លានដុល្លារអាមេរិក សម្រាប់ទាំងពីរភាគី គឺភាគីជាតិ និងអន្តរជាតិនៃ អ.វ.ត.ក ។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោកឃ្នុត វ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃអ.វ.ត.ក បានថ្លែងថា៖ “យើងខ្ញុំសូមស្វាគមន៍ចំពោះការអនុម័តលើគម្រោងថវិកាថ្មីនេះ និងសូមអំពាវនាវដ៏ទទូចដល់សហគមន៍ម្ចាស់ជំនួយ បន្តផ្តល់ជំនួយហិរញ្ញវត្ថុចាំបាច់ដល់ អ.វ.ត.ក ដើម្បីអនុវត្តដោយជោគជ័យលើអាណត្តិការងាររបស់ខ្លួន”។

ព័ត៌មានពិស្តារអំពីគម្រោងថវិការបស់ អ.វ.ត.ក អាចរកបាននៅ៖

https://www.eccc.gov.kh/en/about-eccc/finances/revised-eccc-budget-2016-2017

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*

**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ៩៣៦
ទូរស័ព្ទលើតុ: +៨៥៥ (0) ២៣ ៨៦០ ១៩១
សារអេឡិចត្រូនិក៖ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ: +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh